ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

## សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធ ដាក់ឱ្យដំណើរការជាផ្លូវការ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ

នៅខេត្តកំពង់ធំ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤

សូមគោរព :

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាភ្ញៀវកិត្តិយស ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការអគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំជាផ្លូវការ នាពេលនេះ ។ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំនេះ គឺជាផ្នែកមួយនៃសមិទ្ធផលសង្គមខាងវិស័យធនាគារថ្មីមួយបន្ថែមទៀត សម្រាប់ប្រជាជននិងអាជ្ញាធរខេត្តកំពង់ធំប្រើប្រាស់ និងអាស្រ័យផលរួមគ្នា ។ អគារសាខាធនាគារជាតិនៃខេត្តកំពង់ធំ ត្រូវបានរៀបចំឡើងដើម្បីរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងចូលរួមផ្សព្វផ្សាយចលនាប្រឡងប្រណាំងទីក្រុងស្អាតរបស់រាជរដ្ឋាភិបាល ផងដែរ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម អភិបាលខេត្តកំពង់ធំ ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ តំណាងមន្ទីរ-អង្គភាព និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ និងគាំទ្រការសាងសង់អគារនេះ ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះស្មារតីសហប្រតិបត្តិការល្អ ជាប្រពៃណីនេះមានសារៈសំខាន់ជាគន្លឹះធ្វើឱ្យការងារយើងសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗបន្ថែមទៀត ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបាននូវសមិទ្ធផលយ៉ាងច្រើនជូនធនាគារជាតិនៃកម្ពុជា ហើយក៏បានរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០១២០ របស់រាជរដ្ឋាភិបាល ។


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

តាមរយៈរបាយការណ៍របស់ ឯកឧត្តម អភិបាលខេត្ត ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងសូមអបអរសាទរចំពោះស្នាដៃការងារ និងសមិទ្ធផលអភិវឌ្ឍរីកចម្រើននានានៅទូទាំងខេត្តកំពង់ធំ នាពេលនេះ ។ ខេត្តកំពង់ធំ ជាខេត្តមួយមានសក្តានុពលសេដ្ឋកិច្ច ទាំងផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម ជាពិសេសតំបន់ទេសចរណ៍ ដែលមានរមណីយដ្ឋានទេសចរណ៍ធម្មជាតិ ប្រវត្តិសាស្ត្រ និងវប្បធម៌ ហើយហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមជារូបវន្ត ក៏មានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ អគារទីស្នាក់ការថ្មីរបស់សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំនេះ មិនត្រឹមតែបង្ហាញពីការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារ និងហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត នៃសេដ្ឋកិច្ចនិងសង្គមនៅខេត្តកំពង់ធំប៉ុណ្ណោះទេ ថែមទាំងបានរួមចំណែកជួយលើកសោភ័ណភាពខេត្តកំពង់ធំ និងចលនាប្រឡងប្រណាំងទីក្រុងស្អាតនៃខេត្តកំពង់ធំ នាពេលនេះផងដែរ ។

សមិទ្ធផលនៃនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យប្រទេសកម្ពុជាបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងមានការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេស វិស័យសេដ្ឋកិច្ចជាតិ ។ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក កំណើនសេដ្ឋកិច្ចជាតិបានងើបឡើងយ៉ាងឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

ភាពអំណោយផលនេះ ដោយសារស្ថិរភាពនយោបាយល្អ និងការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលទ្រទ្រង់ដោយការរីកចម្រើននៃវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងសំណង់ ។ ជាក់ស្តែង នៅឆ្នាំ២០១៣ កន្លងមក សេដ្ឋកិច្ចមានស្ថានភាពល្អប្រសើរ និងរក្សាបានអត្រាកំណើន ៧,៥% ។ ភាពល្អប្រសើរនេះដោយសាររាជរដ្ឋាភិបាលរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់ ។ នៅឆ្នាំ២០១៤ នេះ តាមការព្យាកររបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចជាតិរំពឹងថានឹងមានអត្រាប្រមាណ ៧,៦% និងអត្រាអតិផរណាស្ថិតនៅក្នុងកម្រិតមួយទាបអាចគ្រប់គ្រងបាន ។

ចំណែកឯ វិស័យធនាគារ ក៏មានការរីកចម្រើនយ៉ាងខ្លាំង ទាំងផ្នែកវិសាលភាព និងទំហំប្រតិបត្តិការ ។ បច្ចុប្បន្ន ប្រព័ន្ធធនាគារនៅកម្ពុជាមាន *(១)*- ធនាគារជាតិនៃកម្ពុជា ដែលមានសាខានៅទូទាំងប្រទេស គឺជាអាជ្ញាធររូបិយវត្ថុជាតិ និងជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ *(២)*- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ការិយាល័យព័ត៌មានឥណទាន និងអង្គការក្រៅរដ្ឋាភិបាលដែលបានធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ។

ការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារ អាចឆ្លុះបញ្ចាំងតាមរយៈ៖

១)- ការរីកចម្រើននៃបណ្តាញសាខា សេវា និងផលិតផលហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនៅទូទាំងប្រទេស

២)- នៅចុងឆ្នាំ២០១៣ ទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារកើនឡើងដល់ប្រមាណ ១៣ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើងប្រមាណ ១៧% ធៀបនឹងខែធ្នូ ឆ្នាំ២០១២

៣)- ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារកើនឡើងដល់ប្រមាណ ៧ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើងប្រមាណ ១៤% ធៀបនឹងឆ្នាំ២០១២ និង

៤)- ឥណទានចំពោះវិស័យឯកជនកើនឡើងដល់ប្រមាណ ៧ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើងប្រមាណ ២៧% ធៀបនឹងឆ្នាំ២០១២ ។ ចំណែកឯ ឥណទានមិនដំណើរការ (NPL) ស្ថិតនៅកម្រិតទាបក្នុងរង្វង់ ២,៧% ។

តាមរយៈរបាយការណ៍របស់លោកនាយកសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា ការកសាងអគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំថ្មីនេះ ពិតជាបានឆ្លើយតបទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ច និងតម្រូវការការងារចាំបាច់ក្នុងការគ្រប់គ្រងនិងសម្របសម្រួលប្រតិបត្តិការរូបិយវត្ថុ ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត ។ អគារនេះត្រូវបានសាងសង់ឡើងដោយបំពាក់ប្រព័ន្ធកុំព្យូទ័រនៅគ្រប់បន្ទប់ធ្វើការ ហើយផ្នែកខាងក្នុងនិងខាងក្រៅអគារមានបំពាក់ប្រព័ន្ធការពារសុវត្ថិភាពទំនើប ។ ចាប់ពីថ្ងៃនេះទៅ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់និងសកម្មក្នុងការផ្តល់សេវារូបិយវត្ថុជូនមន្ទីរ-អង្គភាពរបស់រដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសាធារណជនទូទៅ ជួយសម្រួលដល់ប្រតិបត្តិការទូទាត់ពាណិជ្ជកម្ម និងធ្វើជាឃ្លាំងផ្ទុកទ្រព្យសម្បត្តិរដ្ឋនៅក្នុងខេត្ត ។

សមិទ្ធផលរីកចម្រើនខាងលើនេះ បញ្ជាក់ថា ប្រព័ន្ធធនាគារនៅកម្ពុជាមានភាពរឹងមាំនិងទទួលបានជំនឿទុកចិត្តពីសាធារណជននិងវិនិយោគិនជាតិ-អន្តរជាតិ ។ បច្ចុប្បន្នប្រព័ន្ធធនាគារបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការកៀរគរប្រាក់សញ្ច័យដែលនៅទំនេរឱ្យចូលក្នុងប្រព័ន្ធ ដើម្បីយកទៅផ្តល់ឥណទានសម្រាប់ពង្រីកគម្រោងវិនិយោគនានា ប្រកបដោយប្រសិទ្ធភាព ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបបន្តិចពីប្រវត្តិនៃការប្រែប្រួលមុខងារនិងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាថា បន្ទាប់ពីប្រទេសកម្ពុជាយើងបានអនុវត្តសេដ្ឋកិច្ចទីផ្សារសេរីរួចមក យើងបានកែទម្រង់ប្រព័ន្ធធនាគារពីមួយថ្នាក់ (Mono Banking) ទៅជាប្រព័ន្ធធនាគារពីរថ្នាក់ (Two-Tier Banking) ហើយប្រព័ន្ធទាំងពីរនេះមានមុខងារនិងភារកិច្ចខុសគ្នា ។ កាលពីមុន ក្នុងរបបសេដ្ឋកិច្ចផែនការប្រមូលផ្តុំ ធនាគារជាតិនៃកម្ពុជា និងសាខាធនាគារ

ជាតិនៃកម្ពុជា បានបំពេញមុខងារនិងភារកិច្ចជា ១)-អាជ្ញាធររូបិយវត្ថុ ២)-បេឡាថវិការដ្ឋាភិបាល និង ៣)- អ្នកផ្តល់សេវាកម្មធនាគារ ដូចជាផ្តល់ឥណទាន ទទួលប្រាក់បញ្ញើ និងប្រព័ន្ធទូទាត់ ។ ការធ្វើកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចនិងវិស័យធនាគារ បានផ្លាស់ប្តូរមុខងារនិងភារកិច្ចធនាគារជាតិនៃកម្ពុជានិងសាខារបស់ខ្លួន ពីការអនុវត្តការងារដោយផ្ទាល់ទៅជាអ្នកគ្រប់គ្រង និងដឹកនាំការងារនេះវិញ ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា និងសាខាធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេសបំពេញមុខងារនិងភារកិច្ចជា ៖

១/- បេឡារបស់រតនាគារជាតិ

២/- ធនាគាររបស់ធនាគារ ដែលមានសាខាធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស ដើរតួនាទីជាអ្នកផ្តល់សេវាជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

៣/- ជាអ្នកបែងចែក គ្រប់គ្រង និងកែសម្រួលដល់ចរាចរណ៍ធនបត្រ នៅទូទាំងប្រទេស

៤/- ជាឃ្លាំងទុកដាក់ទ្រព្យសម្បត្តិរបស់រដ្ឋ ប្រកបដោយសុវត្ថិភាព ។

ក្នុងការអនុវត្តមុខងារជាអាជ្ញាធររូបិយវត្ថុ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំនឹងដើរតួនាទីជាអ្នកសម្របសម្រួលចរាចរណ៍រូបិយវត្ថុជាតិ និងជាអ្នកផ្គត់ផ្គង់សាច់ប្រាក់ឱ្យរតនាគារខេត្ត ធនាគារពាណិជ្ជ ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ព្រមទាំងអង្គការឬក្រុមហ៊ុននិងសាធារណជននានា សំដៅរក្សាស្ថិរភាពតម្លៃប្រាក់រៀល និងបង្កើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលបន្ថែមទៀត ឆ្ពោះទៅរកការអនុវត្តកម្មវិធីពង្រឹងអន្តរការិយកម្មធនាគារនិងទីផ្សារហិរញ្ញវត្ថុនៅពេលអនាគត ។

ក្នុងការអនុវត្តមុខងារជាធនាគាររបស់រដ្ឋាភិបាល និងជាធនាគាររបស់ធនាគារ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ នឹងផ្តល់សេវារូបិយវត្ថុជូនមន្ទីរ-អង្គភាពរដ្ឋ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងជួយសម្របសម្រួលចរាចរណ៍សាច់ប្រាក់ និងការទូទាត់ពាណិជ្ជកម្មនៅក្នុងខេត្តកំពង់ធំ ។ ទាំងនេះ គឺជាតួនាទីសំខាន់របស់សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ ។

ក្រៅពីនេះ អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំនេះ មិនត្រឹមតែបង្ហាញពីភាពរឹងមាំនៃវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ដែលមានហេដ្ឋារចនាសម្ព័ន្ធដល់ជនបទប៉ុណ្ណោះទេ ថែមទាំងជួយលើកសោភ័ណភាពដល់ខេត្តកំពង់ធំទៀតផង ជាពិសេស អគារនេះនឹងធ្វើជាឃ្លាំងប្រាក់សម្រាប់ផ្ទុកទ្រព្យសម្បត្តិរដ្ឋឱ្យមានសុវត្ថិភាព ។ សាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ ក៏បំពេញតួនាទីជាភ្នាក់ងារជំរុញការប្រើប្រាស់ប្រាក់រៀលប្រចាំដែនដី ផ្តល់សេវាកម្មធនាគារនិងហិរញ្ញវត្ថុនៅមូលដ្ឋាន និងធ្វើឱ្យប្រជាជនកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មធនាគារ សម្រាប់យកទៅបង្កើនជីវភាពប្រចាំថ្ងៃរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !**

សរុបមក សមិទ្ធផលទាំងនេះ គឺជាសមិទ្ធផលរួមរបស់យើងទាំងអស់គ្នា ជាពិសេស គឺជាសមិទ្ធផលរបស់អាជ្ញាធរនិងបងប្អូនប្រជាជននៅខេត្តកំពង់ធំ ដែលកើតឡើងដោយស្មារតីសហការគ្នាល្អពីអាជ្ញាធរមានសមត្ថកិច្ចប្រចាំដែនដីគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អាជីវករ ពាណិជ្ជករ និងប្រជាជនទូទៅនៅក្នុងខេត្តទាំងមូល ។ សមិទ្ធផលថ្មីនេះត្រូវបានកសាងឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ទីផ្សារ និងរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ហេតុដូច្នេះហើយ ទើបយើងចាត់ទុកសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំនេះ គឺជាសមិទ្ធផលរួមនិងជាមោទនភាពរួមរបស់យើងទាំងអស់គ្នា ។ សូមរួមគ្នាជួយថែរក្សា និងប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឱ្យមានប្រសិទ្ធភាពនិងស្ថិតស្ថេរយូរអង្វែងតរៀងទៅ ។

ខ្ញុំនៅតែមានជំនឿយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាតំណាងអាជ្ញាធរដែនដី មន្ទីរ-អង្គភាពនៅជុំវិញខេត្តកំពង់ធំទាំងអស់ នៅតែបន្តស្មារតីសហការសាមគ្គីជាប្រពៃណីទាំងកម្លាំងកាយនិងកម្លាំងចិត្ត ដើម្បីបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត ។ ស្មារតីសាមគ្គីនិងការប្រើកម្លាំងសរុបបែបនេះ គឺជាកត្តាមួយដ៏សំខាន់បំផុត សម្រាប់កំណត់ជ័យជម្នះនិងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមលើគ្រប់វិស័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សូមមានសុខភាពល្អ ទទួលបានជ័យជម្នះគ្រប់ភារកិច្ច និងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ " **អគារសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ធំ**" ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**